**វិទ្យាស្ថានសភាកម្ពុជា**
**PARLIAMENTARY INSTITUTE OF CAMBODIA**
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី០២ ខែវិច្ឆិកា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- ពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងថៃ មានការកើនឡើងក្នុងឆ្នាំ២០១៨
- ប្រទេសថៃមើលឃើញកំណើនសេដ្ឋកិច្ចខ្ពស់សម្រាប់ឆ្នាំ២០១៨ បន្ទាប់ពីឃើញលទ្ធផលល្អ ក្នុងត្រីមាសទី៣
- ទំនុកចិត្តអ្នកប្រើប្រាស់នៅអាមេរិកនៅតែរឹងមាំ ក្នុងខែតុលា

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងខ្ញុំមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ពាណិជ្ជកម្មរវាងប្រទេសកម្ពុជានិងថៃ មានការកើនឡើង ក្នុងឆ្នាំ២០១៨

យោងតាមកិច្ចសម្ភាសន៍ជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសថៃដែលបានចេញផ្សាយនៅក្នុងគេហទំព័ររបស់កាសែត ភ្នំពេញប៉ុស្តិ៍ បានអោយដឹងថា ពាណិជ្ជកម្មរវាងប្រទេសកម្ពុជានិងថៃ ក្នុងឆ្នាំ២០១៨ បានកើនឡើងរហូតដល់ ១៤,១% ក្នុងរយៈពេល ០៩ខែ ដំបូង ដែលមានទឹកប្រាក់ស្មើនឹង ៣,២ប៊ីលានដុល្លារអាមេរិក។ ការនាំចូលរបស់កម្ពុជាពីប្រទេសថៃបានកើនឡើង ១៩,៣% ស្មើនឹងទឹកប្រាក់ចំនួន ២,៧ប៊ីលានដុល្លារអាមេរិក ដែលលើសពីការទូទាត់នូវការធ្លាក់ចុះការនាំចេញរបស់កម្ពុជាទៅប្រទេសថៃប្រមាណ៦,២%ដែលសរុបជាទឹកប្រាក់ប្រមាណ ៥៤៣,៣លានដុល្លារអាមេរិក។

ក្រសួងពាណិជ្ជកម្មរបស់កម្ពុជារំពឹងថា ពិពណ៌ពាណិជ្ជកម្មក្នុងឆ្នាំ ២០១៩ ដែលនឹងធ្វើនៅប្រទេសថៃ នឹងពង្រឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរអោយកាន់តែល្អប្រសើរបន្ថែមទៀត។

### តារាងប្រចាំសប្តាហ៍៖ ការព្យាករណ៍ការទូទាត់សេវាបំណុលក្រៅប្រទេសរបស់កម្ពុជា

ការទូទាត់សេវាបំណុលក្រៅប្រទេសរបស់កម្ពុជាបានកើនឡើងជាលំដាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយអាចនឹងបន្តកើនឡើងទៀត។ សេវាទូទាត់បំណុលសរុប ដែលរួមមាន ប្រាក់ដើម និងការប្រាក់និងកម្រៃផ្សេងៗ ត្រូវបានប៉ាន់ប្រមាណថា នឹងកើនឡើងដល់ ២៨១,៥លានដុល្លារ នៅឆ្នាំ២០១៨ ដែលកើនឡើង៣៤%បើធៀបទៅនឹងឆ្នាំមុន។ លើសពីនេះទៅទៀត ការព្យាករណ៍បានបង្ហាញថាការទូទាត់អាចនឹងកើនឡើងដល់ ៣២៩,៩ លានដុល្លារនៅឆ្នាំ២០១៩ ៣៩៣,៩លានដុល្លារនៅឆ្នាំ២០២០ និង ៤៩៩,១លានដុល្លារ នៅឆ្នាំ២០២២។

ការកើនឡើងនេះ គឺដោយសារតែការរំពឹងទុកការកើនឡើងនៃប្រាក់កម្ចីពីខាងក្រៅពីមួយឆ្នាំទៅមួយឆ្នាំ ក៏ដូចជាការចំណាយការប្រាក់ខ្ពស់ទៅលើប្រាក់កម្ចី។

**ការព្យាករណ៍ការទូទាត់សេវាបំណុលក្រៅប្រទេសរបស់កម្ពុជា**




ប្រភព៖ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៨, ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា

# ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ថៃមើលឃើញកំណើនសេដ្ឋកិច្ចខ្ពស់សម្រាប់ឆ្នាំ២០១៨ បន្ទាប់ពីឃើញលទ្ធផលល្អ ក្នុងត្រីមាសទី៣

សកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសថៃអាចនឹងកើនឡើងដល់ ៤,៥% ក្នុងឆ្នាំ២០១៨ គឺខ្ពស់ជាងការប៉ាន់ស្មាន ដែលមានចំនួន ៣,៩% ក្នុងឆ្នាំ២០១៧ បើយោងតាមការិយាល័យគោលនយោបាយសារពើពន្ធ របស់ក្រសួងហិរញ្ញវត្ថុនៃប្រទេសថៃ។ កំណើននេះត្រូវបានជំរុញដោយការកើនឡើងនៃការចំណាយវិស័យឯកជន ការប្រើប្រាស់របស់បុគ្គល និងការវិនិយោគ ជាពិសេសការវិនិយោគធំៗក្នុងត្រីមាសទី៣។ កម្មវិធីប័ណ្ណធានារ៉ាប់រងរបស់រដ្ឋក៏បានរួមចំណែកផងដែរក្នុងការជំរុញចំណាយរបស់វិស័យឯកជន។

ទោះជាយ៉ាងណាក៏ដោយ ការិយាល័យគោលនយោបាយសារពើពន្ធបានពន្យារពេលព្យាករណ៍កំណើនសេដ្ឋកិច្ច សម្រាប់ឆ្នាំ២០១៩ ដោយសារតែសង្គ្រាមពាណិជ្ជកម្មអាមេរិកបានធ្វើអោយទិន្នន័យមានភាពស្មុគស្មាញ សម្រាប់ក្រសួងយកទៅប្រើប្រាស់ដើម្បីរៀបចំការព្យាករណ៍របស់ខ្លួន។ របាយការណ៍នោះ បានឱ្យដឹងថា របាំងពាណិជ្ជកម្មរបស់អាមេរិក មានផលប៉ះពាល់តិចតួចប៉ុណ្ណោះលើការនាំចេញ ដោយកំណើននាំចេញបានធ្លាក់ចុះមកនៅត្រឹម ៨,0% ក្នុងត្រីមាសទី៣ បើធៀបទៅនឹងការប៉ាន់ស្មានដែលមាន ៩,៧%។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## ទំនុកចិត្តអ្នកប្រើប្រាស់នៅតែរឹងមាំនៅក្នុងខែតុលា

គណៈកម្មាធិការសន្និបាតបានចេញផ្សាយការស្ទង់មតិទំនុកចិត្តអ្នកប្រើប្រាស់ ប្រចាំខែរបស់ខ្លួន នៅថ្ងៃទី៣0 ខែតុលា ដោយបង្ហាញថាទំនុកចិត្តរបស់អ្នកប្រើប្រាស់ បានបន្តកើនឡើងឈានដល់កម្រិតខ្ពស់បំផុតក្នុងរយៈពេល១៨ឆ្នាំ។
ការយល់ឃើញរបស់អ្នកប្រើប្រាស់ទៅលើស្ថានភាពទីផ្សារបច្ចុប្បន្ននៅតែមានភាពវិជ្ជមាន ដោយសារតែកំណើនការងារខ្ពស់។ សមាមាត្រនៃអ្នកប្រើប្រាស់ដែលយល់ឃើញថា លក្ខខណ្ឌអាជីវកម្មមាន«សភាពល្អ» កើនឡើងពី ៣៩,៩% ដល់៤0,៥% ខណៈអ្នកដែលយល់ឃើញថា លក្ខខណ្ឌអាជីវកម្មមាន«សភាពអាក្រក់» ធ្លាក់ចុះពី៩,៦%ទៅ៩,២%។
ការវាយតម្លៃទីផ្សារការងាររបស់អ្នកប្រើប្រាស់ គឺមានលក្ខណៈល្អប្រសើរផងដែរ។ អ្នកដែលអះអាងថាការងារ "មានចំនួនច្រើន" បានកើនឡើងពី៤៤,១% ដល់ ៤៥,៩% ខណៈអ្នកដែលអះអាងថាការងារ "គឺពិបាករក" បានថយចុះពី១៤,១% មក ១៣,២%។

# ព័ត៌មានសម្រាប់សប្ដាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្ដាហ៍ខាងមុខនេះរួមមាន៖ កំណើនផ.ស.ស របស់ប្រទេសឥណ្ឌូនេស៊ីនិងប្រទេសហ្វីលីពីន ប្រចាំត្រីមាសទី៣ សំរាប់ឆ្នាំ២០១៨ តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ចិនសំរាប់ខែតុលា និងសេចក្ដីសម្រេចស្ដីពីអត្រាការប្រាក់របស់គណៈកម្មការបើកចំហរទីផ្សាររបស់រដ្ឋសហព័ន្ធនៅអាមេរិក។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្ដាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី០៥ ខែវិច្ឆិកា

- កំណើនផ.ស.សរបស់ប្រទេសឥណ្ឌូនេស៊ី សំរាប់ត្រីមាស ទី៣ ឆ្នាំ២០១៨
- ទំនុកចិត្តរបស់អ្នកប្រើប្រាស់ នៅប្រទេសឥណ្ឌូនេស៊ី សំរាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- ទុនបម្រុងរូបិយប័ណ្ណបរទេសរបស់កូរ៉េខាងត្បូង សំរាប់ខែតុលា
- កិច្ចប្រជុំគោលនយោបាយរូបិយវត្ថុរបស់ជប៉ុន សំរាប់ខែមករា
- សន្ទស្សន៍តម្លៃលក់រាយរបស់ហ្វីលីពីន សំរាប់ខែកញ្ញា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ម៉ាឡេស៊ី សំរាប់ខែកញ្ញា
- ទិន្នន័យលក់រាយរបស់ថៃ សំរាប់ខែសីហា

ថ្ងៃអង្គារ ទី០៦ ខែវិច្ឆិកា

- ការបោះឆ្នោតពាក់កណ្តាលអាណត្តិនៅសហរដ្ឋអាមេរិក
- អត្រាអតិផរណារបស់ប្រទេសហ្វីលីពីន សំរាប់ខែតុលា
- ទិន្នន័យលក់រាយនៅប្រទេសឥណ្ឌូនេស៊ី សំរាប់ខែកញ្ញា
- ទិន្នន័យចំណាយប្រចាំគ្រួសារនៅជប៉ុន សំរាប់ខែកញ្ញា
- គណនីចរន្តរបស់កូរ៉េខាងត្បូង សំរាប់ខែកញ្ញា

ថ្ងៃពុធ ទី០៧ ខែវិច្ឆិកា

- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់តៃវ៉ាន់ សំរាប់ខែតុលា
- អត្រាប្តូរប្រាក់របស់ហ្វីលីពីន សំរាប់ខែតុលា
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ហ្វីលីពីន សំរាប់ខែតុលា

ថ្ងៃព្រហស្បតិ៍ ទី០៨ ខែវិច្ឆិកា

- គណនេយ្យចរន្តរបស់ជប៉ុន សំរាប់ខែកញ្ញា
- ផ.ស.ស.របស់ហ្វីលីពីន សំរាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- ទំនុកចិត្តរបស់អ្នកប្រើប្រាស់នៅប្រទេសថៃ សំរាប់ខែតុលា
- សេចក្តីសម្រេចចិត្តស្តីពីអត្រាការប្រាក់នៅម៉ាឡេស៊ី
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់ចិន សំរាប់ខែតុលា

ថ្ងៃសុក្រ ទី០៩ ខែវិច្ឆិកា

- អតិផរណារបស់ចិន សំរាប់ខែតុលា
- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់របស់ FOMC នៅសហរដ្ឋអាមេរិក
- គណនេយ្យចរន្តរបស់ឥណ្ឌូនេស៊ី សំរាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- សន្ទស្សន៍តម្លៃរបស់អ្នកផលិតនៅសហរដ្ឋអាមេរិក សំរាប់ខែតុលា
- ចំនួនអ្នកគ្មានការងារធ្វើនៅម៉ាឡេស៊ី សំរាប់ខែកញ្ញា
- ផលិតកម្មឧស្សាហកម្មរបស់ម៉ាឡេស៊ី សំរាប់ខែកញ្ញា
- ទិន្នន័យលក់រាយរបស់ម៉ាឡេស៊ី សំរាប់ខែកញ្ញា